អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour Suprême
N⁰:.......អ.វ.ត.ក/អ.ជ.ត.ក

# បទបញ្ជាផ្ទៃក្នុងគ្រប់គ្រងសាលសវនាការក្នុងថ្ងៃសវនាការ

ដើម្បីរក្សានូវសណ្តាប់ធ្នាប់ របៀបរៀបរយ សន្តិសុខ និងដំណើរការល្អក្នុងពេលសវនាការ ប្រធានអង្គជំនុំជម្រះតុលាការកំពូលសម្រេចដាក់ចេញនូវបទបញ្ជាផ្ទៃក្នុងគ្រប់គ្រងសាលសវនាការ ក្នុងអំឡុងពេលសវនាការលើបណ្តឹងសាទុក្ខដូចខាងក្រោម៖

១-អ្នកដែលមានបំណងចូលរួមក្នុងសាលសវនាការទាំងអស់ ត្រូវមានវត្តមានក្នុងសាលសវនាការ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឲ្យបានមុនម៉ោង៨ និង៣០ នាទីព្រឹក និងមុនម៉ោង ១ និង៣០ នាទីល្ងាច។

២-សាធារណៈជននិងភាគីទាំងអស់ ត្រូវក្រោកឈរនៅពេលដែលក្រឡាបញ្ជីបញ្ជាក់ថា "ក្រោកឈរ"ហើយត្រូវអង្គុយចុះ នៅពេលដែលប្រធានអង្គជំនុំជម្រះប្រកាសឲ្យអង្គុយចុះ។

៣-អ្នកចូលរួមក្នុងសាលសវនាការ ត្រូវមានអាកប្បកិរិយាថ្លៃថ្នូរ សមរម្យជានិច្ច។ អ្នកចូលរួម ត្រូវស្លៀកពាក់សមរម្យ មិនត្រូវបង្ហាញពាក្យស្លោក ការគាំទ្រដល់ភាគីណាមួយនៃដំណើរការនីតិវិធី ឬ ប្រើពាក្យសំដីដែលមិនសមរម្យឡើយ។

E.C.C.C * C.E.T.C. SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME

៤-ហាមយកម៉ាស៊ីនថតរូបភាព ម៉ាស៊ីនថតវីដេអូ ឧបករណ៍ថតសម្លេង និងឧបករណ៍បំពងសម្លេងគ្រប់ប្រភេទចូលក្នុងសាលសវនាការ លើកលែងតែមានការអនុញ្ញាតពីប្រធានអង្គជំនុំជម្រះតុលាការកំពូល។

៥-ហាមជក់បារី ឬ យកចំណីអាហារ ភេសជ្ជៈគ្រប់ប្រភេទ ចូលក្នុងសាលសវនាការ។

៦-ហាមយកអាវុធជាតិផ្ទុះគ្រប់ប្រភេទ ចូលក្នុងសាលសវនាការ លើកលែងតែភ្នាក់ងារសន្តិសុខដែលមានសមត្ថកិច្ច។

៧-ហាមប្រើប្រាស់ទូរសព្ទ័គ្រប់ប្រភេទក្នុងសាលសវនាការ ។ ហាមថតរូបភាព ឬ ថតសម្លេងតាមគ្រប់មធ្យោបាយ លើកលែងតែមានការអនុញ្ញាតពីប្រធានអង្គជំនុំជម្រះតុលាការកំពូល។

៨-ហាមប្តូរកន្លែងអង្គុយ ឬ ដើររហេតរហូតក្នុងសាលសវនាការ។

៩-ហាមទះដៃ ឬស្រែកជ័យឃោស ឬ ស្រែកឡូឡា ឬការធ្វើឲ្យមានសម្លេងខ្លាំងដែលនាំឲ្យរំខានដល់ដំណើរការសវនាការ។

១០-ហាមដើរចេញចូលដោយអនាធិបតេយ្យនៅពេលសវនាការ ។ ការចេញចូលត្រូវមានការអនុញ្ញាតពីកម្លាំងសន្តិសុខរក្សាសណ្តាប់ធ្នាប់ក្នុងសាលសវនាការ។

១១-ហាមកុមារដែលមានអាយុតិចជាង១៦ឆ្នាំ ចូលក្នុងសាលសវនាការ ។ កុមារដែលមានអាយុចាប់ពី១៦ឆ្នាំដល់ក្រោម១៨ឆ្នាំ អាចចូលក្នុងសាលសវនាការបាន ប្រសិនបើគាត់មកជាមួយឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាល លើកលែងតែកុមារណាដែលត្រូវចូលរួមក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី ឬ ជាសាក្សី។

១២-ក្នុងករណីមានបុគ្គលប្រព្រឹត្តល្មើសនឹងបទបញ្ជាផ្ទៃក្នុងនេះ ប្រធានអង្គជំនុំជម្រះតុលាការកំពូលនឹងចាត់វិធានការ ដើម្បីរារាំង ឬ ទប់ស្កាត់ភ្លាម តាមករណីសមស្របផ្អែកតាមវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងបទប្បញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជាជាធរមាន៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១១

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME * E.C.C.C * C.E.T.C *

**គង់ ស្រ៊ឹម**